គាំទ្រថវិកាដោយ CARITAS Schweiz Suisse Svizzera Svizra

Agricultural Development Denmark Asia

CHAIN

# អង្គការ អភិវឌ្ឍន៍សហគមន៍ជនបទ និង បរិស្ថាន (អា.សេ.ដូ)

## Rural Community and Environment Development Organization (RCEDO)

Date: 08th May 2019

Presented by Mr. Sam Serey Wathana
Director of RCEDO.

# ប្រវត្តសង្ខេបរបស់ អង្គការ អាសេដូ (RCEDO)

- Rural Community and Environment Development Organizaion (RCEDO) is Local Non-Government Organization registered with the Ministry of Interior 1998. RCEDO has been delivering a broad range of community development projects in North-West Cambodia, especially Banteay Meanchey, Oddar Meanchey Province, Siem Reap & Battambang since 1998. Over the pass 18 years of operated, RCEDO has working to support to 172 villages, 25 commune 9 districts in Banteay Meanchey, Siem Reap and Oddar Meanchey through:

- Safe drinking water/ household Sanitation &hygiene education
- Agriculture production skills training (Vegetable, Livestock & rice bank)
- Self-help group/ CBO and Agriculture Cooperative formation and inputs support and market linkage.

- Civic engagement for good governance & Social Accountability,
- Community Base Disaster Risk Reduction(CBDRR)/CCA,
- Weapon Reduction projects,

## បច្ចុប្បន្ន អង្គការនៅមានគម្រោងចំនួន ៣ កំពង់ដំណើរការ

ក.គម្រោងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយសហគមន៍(CBDRR-2)

ខ. គម្រោងស៊ីសោម (CISOM/ADDA)

គ. គម្រោងបន្លែផ្លែឈើកម្ពុជា (ឈេន/CHAIN-SNV)

# គំបន់គោលដៅរបស់គម្រោងមានចំនួន៖






# តំបន់គោលដៅរបស់គម្រោងមានចំនួន៖

- ខេត្តបន្ទាយមានជ័យមាន ស្រុកស្វាយចេក និង ស្រុកព្រះនេត្រព្រះ
  - មានចំនួន ៣ឃុំ លើ ២០ភូមិ
- ខេត្តឧត្តរមានជ័យ មានស្រុកចុងកាល់ និង ក្រុងសំរោង
  - មានចំនួន ៦ ឃុំ ៣៦ ភូមិ

## គម្រោង កាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយសហគមន៍

(COMMUNITY BASE DISASTER RISK REDUCTION PROJECT (CBDRR) )

**គោលដៅគម្រោង:**

ជួយអោយប្រសើរឡើងបន្ថែមនូវភាពធនបានរបស់សហគមន៍ជនបទពីការរងឥទ្ធិពល នៃអាកាសធាតុដែលទាក់ទងគ្រោះមហន្តរាយតូចធំ ក្នុង ខេត្តបន្ទាយមានជ័យ ។

**គោលបំណង÷**

- បង្កើនសមត្ថភាពសហគមន៍ និង អ្នកពាក់ព័ន្ធសំខាន់ក្នុងតំបន់គោលដៅក្នុងការរៀបចំទុក និង ការឆ្លើយតបចំពោះគ្រោះធម្មជាតិ ដែលជួយអោយកាត់បន្ថយបាននូវភាពងាយរងគ្រោះរបស់ពួកគេនូវរាល់ហានិយភ័យនានា។

# លទ្ធផលទី១ សម្រេចបាន

**លទ្ធផលរំពឹងទុកទី១៖** អាជ្ញាធរពាក់ព័ន្ធ និងសហគមន៍ប្រើប្រាស់ចំណេះដឹងរបស់ពួកគេដើម្បីកាត់បន្ថយយ៉ាងមានប្រសិទ្ធភាពចំពោះផលប៉ះពាល់ក្នុងការប្រើប្រាស់ទឹក និងការប្រកបរបរចិញ្ចឹមជីវិត

## លទ្ធផលសម្រេចបាន៖

- សិក្ខាសាលាបង្ហាញពីគម្រោង CBDRR-II ដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ និងភូមិ ចំនួន៣លើក ប្រព្រឹត្តទៅនៅតាមសាលាឃុំនីមួយៗ ដែលមានអ្នកចូលរួម សរុបចំនួន ៦៨នាក់ ស្រី ៨នាក់ ។
- កសាងឯកសារប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព (HVCA) និងផែនការសកម្មភាពសហគមន៍ (CAP) បាន២០ ភូមិ និងធ្វើបច្ចុប្បន្នភាព១២ភូមិចាស់ ។

- បង្កើតរចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយភូមិចំនួន៨ភូមិថ្មី និងធ្វើបច្ចុប្បន្នភាព ១២ភូមិចាស់ ដែលមានការទទួលស្គាល់ពី គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ ។
- បើកវគ្គបណ្តុះបណ្តាលស្តីពី ទស្សនទាននៃគ្រោះមហន្តរាយ និងការគ្រប់គ្រងគ្រោះមហន្តរាយដល់ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ និងភូមិ ចំនួន៣លើក ដែលមានអ្នកចូលរួមសរុបចំនួន ៧០នាក់ ស្រី ២១នាក់។
- ប្រជុំប្រចាំខែរបស់គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយភូមិ ទាំង២០ភូមិ ដែលមានអ្នកចូលរួមសរុបចំនួន១,៦៤៣នាក់ ស្រី ៧៥៥នាក់ ។
- ចុះហត្ថលេខាអនុស្សារណៈយោគយល់គ្នាជាមួយអនុវិទ្យាល័យគោលដៅទាំង៣ មាន អនុវិទ្យាល័យតាផូ ទានកាំ និងទឹកជោរ ក្នុងការអនុវត្តគម្រោងកាត់បន្ថយហានិភ័យគ្រោះ[illegible] ។

- ចងក្រងបង្កើតក្រុមយុវជននៅអនុវិទ្យាល័យគោលដៅទាំង៣ មានយុវជនសរុប៤៥នាក់ ស្រី ២៦នាក់។
- បើកវគ្គបណ្តុះបណ្តាលស្តីពី ទស្សនទាននៃគ្រោះមហន្តរាយ និងការគ្រប់គ្រងគ្រោះមហន្តរាយដល់  ក្រុមយុវជនអនុវិទ្យាល័យ ចំនួន៣លើក ដែលមានអ្នកចូលរួមសរុបចំនួន៤៥នាក់ ស្រី ២៦នាក់។
-  បើកវគ្គអប់រំផ្សព្វផ្សាយពីការកាត់បន្ថយហានិភ័យ នៃពហុមុខសញ្ញាគ្រោះថ្នាក់ ដល់ ប្រជាពលរដ្ឋទាំង២០ភូមិ (ក្នុង១ភូមិ៤លើក) ដែលមានអ្នកចូលរួមសរុបចំនួន ២,០៨៧នាក់ ស្រី១,៥១៦នា
- បើកវគ្គអប់រំផ្សព្វផ្សាយពីការកាត់បន្ថយហានិភ័យ នៃពហុមុខសញ្ញាគ្រោះថ្នាក់ និង អនាម័យ ទឹកស្អាតដល់ សិស្សានុសិស្សអនុវិទ្យាល័យចំនួន៤លើក ដែលមានអ្នកចូលរួមសរុប ២៧៦នាក់ ស្រី ១៧៧នាក់។

- បានសហការជាមួយមន្ទីរអប់រំ និងការិយាល័យអប់រំយុវជន និងកីឡា បើកវេទិកាអប់រំផ្សព្វផ្សាយស្តីពី ការកាត់បន្ថយហានិភ័យ នៃពហុមុខសញ្ញាគ្រោះថ្នាក់ និងអនាម័យទឹកស្អាត ចំនួន២លើកដល់សិស្សានុសិស្សកម្រិតមធ្យមសិក្សា ដែលមានអ្នកចូលរួមសរុបចំនួន ១,៣៩៧នាក់ ស្រី ៩៨៧នាក់។

- បង្កើតសម្ភារអប់រំផ្សព្វផ្សាយ ស្តីពី ប្រការគួរយល់ដឹងពី មុខសញ្ញាគ្រោះថ្នាក់បង្ករពីធម្មជាតិ និងមនុស្ស ចំនួន២៦ ឃុត សម្រាប់ ថ្នាក់ភូមិ និងអនុវិទ្យាល័យ ។

# លទ្ធផលទី១ សម្រេចបាន















RCEDO












ប្រការគួរយល់ដឹងពីគ្រោះទឹកជំនន់
CARITAS




ប្រការគួរយល់ដឹងពីគ្រោះរាំងស្ងួត
CARITAS




ប្រការគួរយល់ដឹងពីគ្រោះខ្យល់ព្យុះ
CARITAS




ប្រការគួរយល់ដឹងពីរន្ទះ ឬ រន្ទះបាញ់
CARITAS




ប្រការគួរយល់ដឹងពីអនាម័យទឹក
CARITAS

# លទ្ធផលទី២ សម្រេចបាន

**លទ្ធផលរំពឹងទុកទី២៖** **សហគមន៍នៅក្នុងភូមិគោលដៅ អនុវត្តកសិកម្មបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងមុខរបរចិញ្ចឹមជីវិត ដើម្បីបង្កើនប្រាក់ចំណូល និងមាននិរន្តរភាព**

- បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នានៃភាពជាដៃគូរជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងការអនុវត្តបច្ចេកទេសកសិកម្មបន្សាំនឹងការប្រែប្រួលអាកាសធាតុ (ដំណាំស្រូវ ដំណាំបន្លែ និងការចិញ្ចឹមសត្វ) ។
- បានចុះប៉ាន់ប្រមាណលទ្ធភាព ប្រជាកសិករចំនួន១០០គ្រួសារ ក្នុងការធ្វើកសិកម្មបន្សាំនឹងការប្រែប្រួលអាកាសធាតុ (ដាំបន្លែសុវត្ថិភាព និងចិញ្ចឹមមាន់ ទា ត្រី) ។
- បានសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បើកវគ្គបណ្តុះបណ្តាលអំពី ការដាំដុះ បន្លែសុវត្ថិភាព ដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដល់កសិករចំនួន ២៨នាក់ ស្រី ២២នាក់ ។

- បានសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បើកវគ្គបណ្តុះ បណ្តាល អំពីការចិញ្ចឹមសត្វ មាន់ ទា ដែលបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដល់កសិករចំនួន ២៥ នាក់ ស្រី ១៥នាក់ និង ការចិញ្ចឹមត្រីចំនួន ១៨នាក់

  ស្រី ១៣នាក់។

- បានបង្កើតក្រុមជួយខ្លួនឯង (ក្រុមថ្មី) ចំនួន៥ក្រុម ដែលមានសមាជិកសរុប ចំនួន ៩៦ នាក់ ស្រី៨៤នាក់។
- បានគាំទ្រទុនសំរាប់ក្រុមជួយខ្លួនឯង (ក្រុមសន្សំប្រាក់) ចំនួន៤ក្រុម ដោយក្នុង១ក្រុម ទទួលបានថវិកាចំនួន ១លានរៀល (250$) ។
- បានគាំទ្រទុនសំរាប់កសិករគំរូ ដាំបន្លែសុវត្ថិភាពជាលក្ខណៈអាជីវកម្មចំនួន៤គ្រួសារ និងគ្រួសារដាំហូបចំនួន១២ គ្រួសារ។
- បានគាំទ្រទុនសំរាប់កសិករគំរូ ចិញ្ចឹមសត្វមាន់ ទា និងត្រី ជាលក្ខណៈអាជីវកម្ម ចំនួន ៥គ្រួសារ និងចិញ្ចឹមលក្ខណៈគ្រួសារចំនួន១២ គ្រួសារ។

# លទ្ធផលទី២ សម្រេចបាន





















RCEDO













# លទ្ធផលទី៣ សម្រេចបាន

**លទ្ធផលរំពឹងទុកទី៣៖** **ការគ្រប់គ្រងធនធានទឹកសហគមន៍ ត្រូវបាន ពង្រឹងអោយកាន់តែប្រសើរឡើង និង បង្កើនគុណភាពទឹក នៅក្នុងសហគមន៍គោលដៅអោយមាននិរន្តភាព**

**លទ្ធផលសម្រេចបាន៖**

- បានចុះហត្ថលេខាអនុស្សារណៈយោគយល់គ្នាជាមួយ មន្ទីរធនធានទឹក និងឧតុនិយមខេត្ត ក្នុងការអនុវត្តសកម្មភាពគម្រោងដែលទាក់ទងនឹង ការគ្រប់គ្រងទឹក ។
- បានសហការជាមួយមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត ចុះសិក្សាប៉ាន់ប្រមាណអំពីការស្តារប្រឡាយទឹកសហគមន៍ ការដាក់លូរំដោះទឹក និងការស្តារស្រះសហគមន៍នៅក្នុងតំបន់គោលដៅគម្រោង ។
- បានកែលម្អប្រឡាយទឹកសហគមន៍១ខ្សែ ប្រវែង២,០០០ម៉ែត្រ និងដាក់លូរំដោះទឹកចំនួន ៣កន្លែង ។

- បានគាំទ្រពាងទឹកចំណុះ២,០០០លីត្រ ចំនួន១១០ពាងដល់១១០គ្រួសារ ធុងចម្រោះទឹកចំនួន១០០ ដល់១០០គ្រួសារ ទរត្រងទឹកភ្លៀងចំនួន១៥គ្រួសារ និងសម្ភារៈសំណង់ (មានឥដ្ឋ និងស៊ីម៉ង់ត៍) សម្រាប់ធ្វើជើងទម្រពាង ដល់៣០គ្រួសារ។

- បានសហការជាមួយមន្ទីរធនធានទឹក និងឧតុនិយម បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ស្តីពី ប្រតិបត្តិការ និងការថែទាំ ប្រព័ន្ធធារាសាស្ត្រ ចំនួន ២វគ្គ ជូនដល់ គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក អាងត្រពាំងថ្ម អាងស្ពានស្រែង អាងពន្លៃ អាងប្រាសាទប្រាំ និងអនុគណៈកម្មាធិការ ដែលមានអ្នកចូលរួមសរុបចំនួន ៤៨ នាក់ ស្រី ២នាក់។

- បានសហការជាមួយសហគមន៍កសិករប្រើប្រាស់ទឹក ក្នុងតំបន់គោលដៅ និងក្រៅតំបន់គោលដៅ ចុះផ្សព្វផ្សាយពី សារាចរណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការថែរក្សាទឹកទុក ច្បាប់ប្រើប្រាស់ទឹក និងការប្រមូលវិភាគទាន ដល់ប្រជាកសិករ ដែលមានអ្នកចូលរួម សរុបចំនួន ២៥០នាក់ ស្រី ១៦៥នាក់។

- បានរៀបចំទិវាដាំកូនឈើចម្រុះ ចំនួន៤,៤៨០ដើម ដែលមានអ្នកចូលរួមសរុបចំនួន ៥២២នាក់ ស្រី ២១០នាក់។

- បានសហការជាមួយមន្ទីរធនធានទឹក និងឧតុនិយម ដឹកនាំគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកទាំងក្នុង និងក្រៅតំបន់គោលដៅគម្រោង ធ្វើទស្សនៈកិច្ចសិក្សាអំពីការគ្រប់គ្រង ប្រតិបត្តិការ ការថែទាំ ប្រព័ន្ធធារាសាស្ត្រ និង ការប្រមូលវិភាគទានរបស់គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកស្ទឹងជីនិត ក្នុងខេត្តកំពង់ធំ ដែលមានអ្នកចូលរួម សរុបចំនួន ៣១ នាក់ ស្រី៤ នាក់។

- បានចុះប្រជុំស្តីពី ការអនុវត្តការងារ ការគ្រប់គ្រងទឹក ជាមួយសហគមន៍កសិករប្រើប្រាស់ទឹក ក្នុងតំបន់គោលដៅ និងក្រៅតំបន់គោលដៅ ចំនួន ២លើក ដែលមានអ្នកចូលរួម សរុបចំនួន ៣១នាក់ ស្រី ៣នាក់។

# លទ្ធផលទី៣ សម្រេចបាន
























Water filters Distribution






# លទ្ធផលទី៤ សម្រេចបាន

**លទ្ធផលរំពឹងទុកទី៤៖** **សិស្សានុសិស្សមានភាពរីករាយជាមួយបរិស្ថានសុវត្ថិភាព និង មានផាសុខភាពនៅក្នុងសាលាបៃតង និងអាចយកចំណេះដឹងផ្សេងៗពីសាលាបៃតង ទៅអនុវត្តនៅផ្ទះរបស់ពួកគេ**

- បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នានៃភាពជាដៃគូរជាមួយមន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា ស្រុកស្វាយចេក និងស្រុកព្រះនេត្រព្រះ អនុវិទ្យាល័យចំនួន៣ និងសាលាបឋមសិក្សាចំនួន៣ ក្នុងការអនុវត្តកម្មវិធីសាលាបៃតង និងការកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយនៅសាលារៀន។
- បើកវគ្គបណ្តុះបណ្តាលអំពីដំណើរការនៃសាលាបៃតងដល់ នាយកសាលា លោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធ ដែលមានអ្នកចូលរួមចំនួន ៤៥នាក់ ស្រី ១៦នាក់ សម្របសម្រួលដោយអ្នកជំនាញផ្នែកសាលាបៃតងមកពីប្រទេសស្វីស។

- បានប្រជុំបង្ហាញលទ្ធផលរយៈពេល១ឆមាស នៃការអនុវត្តកម្មវិធីសាលាបៃតងជូនដល់មន្ទីរអប់រំ ការិយាល័យអប់រំ និងសាលាបឋមសិក្សាគោលដៅទាំង៨ ដែលមាន អ្នកចូលរួមសរុបចំនួន ២៥ នាក់ ស្រី ៥នាក់។
- កសាងហេដ្ឋារចនាសម្ព័ន្ធអនាម័យស្តង់ដារ និងទឹកស្អាតសម្រាប់បរិភោគ ដោយបានផ្តល់នូវធុងចម្រោះទឹក តាមសាលាបឋមសិក្សាគោលដៅគម្រោង
- បង្កើតនូវប្រព័ន្ធគ្រប់គ្រងកាកសំណល់ ដោយបានផ្តល់ធុងញែកសម្រាម និងធុងដាក់សម្រាម
- គាំទ្រលើសម្ភារអនាម័យដល់សាលាបឋមសិក្សាគោលដៅទាំង៣

# លទ្ធផលទី៤ សម្រេចបាន















RCEDO













# លទ្ធផល ទី៥ សម្រេចបាន

**លទ្ធផលរំពឹងទុកទី៥៖ អាជ្ញាធរថ្នាក់ ខេត្ត ស្រុក ឃុំ ដាក់បញ្ចូលការងារកាត់បន្ថយហានិភ័យ នៃគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ និង ការគ្រប់គ្រងធនធានទឹក នៅក្នុងផែនការអភិវឌ្ឍន៍**

- បានចូលរួមសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក នៅស្រុកស្វាយចេក និងស្រុកព្រះនេត្រព្រះ ដោយបានដាក់បញ្ចូលផែនការសកម្មភាពសហគមន៍ (CAP) ទាំង២០ភូមិ ទៅក្នុងផែនការវិនិយោគស្រុក ។
- បានប្រជុំបណ្តាញអង្គការមិនមែនរដ្ឋាភិបាលក្នុងខេត្តចំនួន២លើក ដើម្បី ចែករំលែកនូវព័ត៌មានអំពីការអនុវត្តសកម្មភាព តំបន់គោលដៅ បញ្ហាប្រឈម អនុសាសន៍ និងផែនការសកម្មភាពបន្ត ដែលមានអ្នកចូលរួមសរុបចំនួន២៨នាក់ ស្រី ៧នាក់។

- បានបើកកិច្ចប្រជុំស្តីពី ការបង្ហាញលទ្ធផលរយៈពេល១ឆ្នាំ នៃការអនុវត្តការងារ គម្រោងកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយសហគមន៍ ជំហ៊ាន២ និងផែនការ សកម្មភាពអនុវត្តបន្ត ២០១៩-២០២០ ជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-ស្រុក ដែលមានអ្នកចូលរួមសរុប ៤៤នាក់ ស្រី២នាក់។










MOU SIGNING
CEREMONY



# Thanks you for your attention